# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ១៩១ សជណ ធទឧ

## សេចក្តីជូនដំណឹង
## ស្តីពី ស្ថានភាពអាកាសធាតុ

បន្ទាប់ពីបានធ្វើការតាមដាន និងព្យាករណ៍លើស្ថានភាពអាកាសធាតុរួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា : មកដល់ម៉ោង 10 h 00 ព្រឹក ថ្ងៃទី 16 ខែកញ្ញា ឆ្នាំ 2014 នេះ ព្យុះទី 15 ឈ្មោះ **កាល់ម៉េជី** (KALMAEGI) បាន និងកំពុងស្ថិតនៅលើសមុទ្រចិនខាងត្បូង ។ តាមការព្យាករណ៍ ព្យុះនេះនឹងធ្វើដំណើរទៅដល់ឆ្នេរប្រទេសវៀតណាមភាគខាងជើង នៅយប់ថ្ងៃទី 17 ខែកញ្ញា ឆ្នាំ 2014 ។

ស្ថានភាពបែបនេះ នឹងធ្វើឱ្យតំបន់មាត់សមុទ្រនៃព្រះរាជាណាចក្រកម្ពុជា មានភ្លៀងពីបង្គួរទៅច្រើន ព្រមទាំងមានខ្យល់បក់បោកខ្លាំង ជាពិសេសនៅខេត្តកោះកុង និងខេត្តព្រះសីហនុ ។ រលកសមុទ្រអាចមានកំពស់ពី 1 m ទៅ 2,50 m ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន ពិសេសចំពោះបងប្អូនប្រជានេសាទ និងអ្នកធ្វើដំណើរតាមសមុទ្រ សូមបង្កើនការយកចិត្តទុកដាក់ខ្ពស់ ដើម្បីចៀសវាងបាននូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១៤

**រដ្ឋមន្ត្រី**

**លឹម គានហោ**

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh